# ផលប៉ះពាល់
## លើស្ត្រីមេគ្រួសារ ដោយសារគ្រោះទឹកជំនន់





# មាតិកា

**សេចក្តីផ្តើម** ៣

១. បញ្ហារបស់ស្ត្រីទាក់ទងនឹងគ្រោះទឹកជំនន់ ៤

២. អនុសាសន៍ដើម្បីដោះស្រាយសេចក្តីត្រូវការរបស់ស្ត្រីមេគ្រួសារ ៦

៣. តួនាទីរបស់ស្ត្រីនៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ៨

៤. សកម្មភាពអនុវត្ត ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ស្ត្រីមេគ្រួសារ ក្រោមគំរោង "**ពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់**" ផ្នែកទី៤ កម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់ របស់គណៈកម្មការទន្លេមេគង្គ ១០

៥. បទពិសោធន៍ និង មេរៀនទទួលបានពីការអនុវត្តន៍គំរោងសាកល្បង ១១



# សេចក្ដីផ្ដើម

ដោយមើលឃើញពីបញ្ហាស្ត្រី ជាពិសេស ស្ត្រីមេគ្រួសារ ដែលរស់នៅតាមតំបន់ប្រឈមមុខនឹង គ្រោះទឹកជំនន់ មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី បានសហការជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និង មន្ទីរកិច្ចការនារីខេត្ត និង ការិយាល័យកិច្ចការ នារីស្រុកបានធ្វើការសិក្សាលើ ផលប៉ះពាល់លើស្ត្រីមេគ្រួសារដោយសារទឹកជំនន់ ដើម្បីកំនត់ពីបញ្ហា ដែលគេជួបប្រទះ សេចក្តីត្រូវការ និង ដំណោះស្រាយដែលអាចដោះស្រាយបានរបស់ស្ត្រីមេគ្រួសារ ទាក់ទងនឹងគ្រោះទឹកជំនន់ ។ លទ្ធផល នៃការសិក្សា ត្រូវបានយកមកធ្វើសិក្ខាសាលាថ្នាក់ខេត្ត នៅតាមខេត្តគោលដៅ (ខេត្តកណ្ដាល និង ព្រៃវែង) កាលពីឆ្នាំ២០០៦ ។ ផ្អែកលើលទ្ធផលសិក្សា និង សិក្ខាសាលាបានបង្ហាញថា ស្ត្រីជាមេគ្រួសារក្រីក្រ មេម៉ាយ និងមានកូនច្រើនដែលរស់នៅ តាមតំបន់ទំនាបដងទន្លេមេគង្គ និង ដៃរបស់វា តែជួបប្រទះ និង ប្រឈមខ្លាំងជាងគេទៅនឹងគ្រោះភ័យនៃទឹកជំនន់ប្រចាំឆ្នាំ ដោយសារពួកគេមានកំរិតជីវភាពទន់ខ្សោយ ក៏ដូចជាសមត្ថភាព និង លទ្ធភាពក្នុងការឆ្លើយតបនឹងគ្រោះទឹកជំនន់ នៅមានកំរិតទាប ។ ការសិក្សាក៏បានបង្ហាញផងដែរ ពីភាពចន្លោះនៃការយកចិត្តទុកដាក់ដោះស្រាយបញ្ហាដែលស្ត្រីមេគ្រួសារក្រីក្រកំពុងជួបប្រទះ ទាក់ទងនឹងគ្រោះទឹកជំនន់ពីបណ្ដាស្ថាប័នរដ្ឋាភិបាល និង អង្គការសង្គមស៊ីវិលនានា ដែលធ្វើការផ្ដោតសំខាន់លើស្ត្រី នៅក្នុងការអនុវត្តន៏កម្មវិធីនានាទាក់ទងនឹងការកាត់បន្ថយផលប៉ះពាល់លើស្ត្រីមេគ្រួសារដោយសារគ្រោះទឹកជំនន់ ។ ដើម្បីដោះស្រាយបញ្ហាទាំងអស់ទាក់ទងនឹងស្ត្រីមេគ្រួសារ សិក្ខាសាលាថ្នាក់ខេត្តបានផ្ដល់អនុសាសន៏ និង ដំណោះស្រាយមួយចំនួនដែលអាចដោះស្រាយបាន សំដៅធ្វើឱ្យស្ថានភាពស្ត្រីមេគ្រួសារក្រីក្រ និងជីវភាពរស់នៅរបស់ពួកគេបានប្រសើរឡើង ដូចជា : ការផ្ដល់សេវាកម្មផ្នែកសេដ្ឋកិច្ច ផ្នែកអប់រំ ផ្នែកសុខភាព មុខជំនាញ-វិជ្ជាជីវៈ យេនឌ័រ ពិសេស លើពិតមានសំខាន់ៗ ទាក់ទិនបញ្ហាសុវត្ថិភាពទឹកជំនន់ ។

គោលបំណងសំខាន់នៃឯកសារនេះ គឺដើម្បីចែករំលែក និងផ្សព្វផ្សាយពីបញ្ហារបស់ស្ត្រីមេគ្រួសារ ដែលកំពុងជួបប្រទះការគំរាមកំហែងដោយសារមុខសញ្ញាបង្កគ្រោះមហន្តរាយនានា ជាពិសេសគ្រោះទឹកជំនន់ នៅតាមដងទន្លេមេគង្គ និងតំបន់ទំនាបនានា ។ ម្យ៉ាងទៀត ដើម្បីចែករំលែកគំនិតផ្ដួចផ្ដើម និងដំណោះស្រាយសមស្រប ដើម្បីទាញការយកចិត្តទុកដាក់ពីស្ថាប័នរដ្ឋាភិបាល អង្គការសង្គមស៊ីវិលនានា ក្នុងការចូលរួមដោះស្រាយបញ្ហាទាំងអស់នេះនៅពេលបច្ចុប្បន្ន និងអនាគត ។





# ១. បញ្ហារបស់ស្ត្រីទាក់ទងនឹងគ្រោះទឹកជំនន់

- **ការផ្ដល់ពត៌មានព្យាករណ៍ពីទឹកជំនន់មានរយៈពេលខ្លី**

ការផ្ដល់ពតិមានព្យាការណ៍ពីកំពស់ទឹកជំនន់ និង ពតិមានប្រកាសភាពអាសន្នមានរយៈពេលខ្លីពេក (តែ៣ថ្ងៃមុន) ក្នុងការត្រៀមលក្ខណៈចាត់វិធានការដើម្បីឆ្លើយតបទៅនឹងគ្រោះទឹកជំនន់ ដូចជា ការជំលៀសទ្រព្យសម្បត្តិ សមាជិកគ្រួសារ និង សត្វចិញ្ចឹមរបស់គេ ទៅកាន់ទីកន្លែងដែលមានសុវត្ថិភាព ។ ស្ត្រីភាគច្រើននៅតាមតំបន់លិចទឹកតាមជនបទមិនអាចទទួលបានពតិមានព្យាករណ៍ និង ពតិមានប្រកាសភាពអាសន្នពីកំពស់ទឹកជំនន់បានទាន់ពេល និង មិនទៀងទាត់ពេលវេលា នៅរដូវទឹកជំនន់ ។

- **ភាពមិនច្បាស់លាស់នៃប្រព័ន្ធផ្ដល់ពត៌មាន និង ទំនាក់ទំនង**

ការបញ្ជូន និង ការទទួលពតិមានព្យាករណ៍ និង ពតិមានប្រកាសភាពអាសន្ន ដល់ស្ថាប័នទទួលបន្ទុកកិច្ចការនារីមិនបានទៀងទាត់ និង ទាន់ពេលវេលា បណ្ដាលមកពីការខ្វះខាតមធ្យោបាយទំនាក់ទំនង និង កង្វះខាតយន្តការក្នុងការទទួល និង បញ្ជូនពតិមាននៅគ្រប់ថ្នាក់ ។

- **ខ្វះខាតទិន្នន័យទាក់ទងនឹងស្ត្រីអំពីបញ្ហាគ្រោះមហន្តរាយ**

មិនមានពតិមានច្បាស់លាស់ទាក់ទងនឹងបញ្ហារបស់ស្ត្រី ឧ. ចំនួនស្ត្រីមេគ្រួសារ និង ស្ត្រីមេគ្រួសារ ដែលមានដី ឬ មិនមានដីផ្ទាល់ខ្លួនសំរាប់បង្កបង្កើនផល ។ល។ ខ្វះខាតវិធីសាស្ត្រ និង និតិវិធីក្នុងការផ្សព្វផ្សាយពតិមានព្យាករណ៍ និង ពតិមានប្រកាសភាពអាសន្នដល់ស្ត្រីនៅតាមតំបន់ជនបទ ជាពិសេស ស្ត្រីមេគ្រួសារ ។

- **ខ្វះខាតយន្តការក្នុងការបញ្ជ្រាបបញ្ហាយេនឌ័រនៅក្នុងការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ**

នៅក្នុងប្រទេសកម្ពុជា បញ្ហាការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យនានា គឺមានសកម្មភាព និង មានលក្ខណៈទូលំទូលាយ ប៉ុន្តែការបញ្ជ្រាបបញ្ហានេះទៅក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ គឺនៅមិនទាន់ មានភាពទូលំទូលាយនៅឡើយទេ ។ ជាពិសេស តួនាទីរបស់ស្ថាប័ន និង អង្គការសង្គមស៊ីវិលទទួលបន្ទុកការងារស្ត្រី មិនទាន់បានយកចិត្តទុកដាក់លើការងារគ្រប់គ្រងគ្រោះមហន្តរាយ ។ ហេតុដូច្នេះ ហើយបានជាវត្តមានរបស់ស្ត្រីនៅក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ នៅមិនទាន់មានភាពសកម្មនៅឡើយ ។

- **មានការចូលរួមតិចតួចរបស់ស្ត្រី**

ជាទូទៅស្ត្រីមិនត្រូវបានគេអោយចូលរួមនៅក្នុងការសំរេចចិត្ត និង ក្នុងការរៀបចំផែនការផ្សេងៗ នៅថ្នាក់មូលដ្ឋាន ជាពិសេស ទាក់ទងនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយ ។ ម្យ៉ាងទៀត ដោយសារទំនៀមទំលាប់ វប្បធម៌ ប្រពៃណី និង ឥរិយាបទរបស់ស្ត្រីខ្លួនឯង ដែលជាហេតុធ្វើអោយមានការខ្វះខាត ក្នុងការចូលរួមរបស់ស្ត្រី ។

- **ខ្វះការពង្រឹងសមត្ថភាព ចំណេះដឹង និង ជំនាញ**

ជាទូទៅស្ត្រីនៅតាមជនបទមានឱកាសបានទទួលការរៀនសូត្រ និង មានជំនាញតិចជាងបុរស ។ ដោយសារគ្រួសាររបស់គេ ឬ ខ្លួនគេសំរេចចិត្តបោះបង់ការរៀនសូត្រ ដើម្បីជួយធ្វើកិច្ចការគ្រួសារ របស់គេ ។ ម្យ៉ាងទៀត ស្ត្រីនៅតាមសហគមន៍មិនសូវបានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលជំនាញខ្លីៗ និងសកម្មភាពរៀនសូត្រតាមរយៈការផ្សព្វផ្សាយបង្កើនការយល់ដឹងដែលគេធ្វើនៅតាមសហគមន៍ ដោយពួកគេជាប់រវល់កិច្ចការផ្ទះ និង កិច្ចការបង្កបង្កើនផលផ្សេង ៗ ។ ហេតុដូច្នេះហើយ បានជា



ស្ត្រីមានចំណេះដឹង ជំនាញនិង សមត្ថភាពទាបតិចតួចបំផុត ។ ដោយសារតែបញ្ហាជីវភាពក្រីក្រ និង ដោយសារស្ត្រីមេគ្រួសារទទួលបន្ទុកធ្ងន់ធ្ងរក្នុងការប្រកបរបរចិញ្ចឹមគ្រួសារ ជាហេតុធ្វើអោយសមាជិកគ្រួសារដែលជាកុមារដែលអាចជួយធ្វើការងារបានត្រូវបោះបង់ចោលការសិក្សាដើម្បីជួយធ្វើការងារគ្រួសារ ។

- **បញ្ហាសុខភាព និង អាហារូបត្ថម្ភ**

ជាពិសេស នៅរដូវទឹកជំនន់ សមាជិកគ្រួសារដែលរស់នៅក្នុងគ្រួសារដែលមានស្ត្រី ជាមេគ្រួសារក្រីក្រ មានបញ្ហាសុខភាពធ្ងន់ធ្ងរ ដោយសារការខ្វះម្ហូបអាហារគ្រប់គ្រាន់ ខ្វះអនាម័យក្នុងការបរិភោគ និង រស់នៅ ខ្វះជំរក ខ្វះទឹកស្អាតសំរាប់ប្រើប្រាស់ និង បរិភោគ ។ ជាពិសេស ស្ត្រីដែលជាមេគ្រួសារ ធ្វើការទាំងឈឺ និង បរិភោគអាហារមិនគ្រប់គ្រាន់ហើយធ្វើការលើសកំលាំង គ្មានពេលសំរាក ដែលជាហេតុធ្វើអោយសុខភាពមានភាពដុនដាបពីមួយថ្ងៃទៅមួយថ្ងៃ ។

- **មានការបោះបង់ចោល និង អំពើហឹង្សាក្នុងគ្រួសារ**

គ្រួសារខ្លះ ត្រូវបានប្តីធ្វើចំណាកស្រុកស្វែងរកការងារនៅកន្លែងឆ្ងាយរយៈពេលយូរមិនវិលត្រឡប់មកវិញ ដោយទុកប្រពន្ធនិងកូននៅឯផ្ទះរកស៊ីចិញ្ចឹមជីវិតដោយខ្លួនឯង ។ ករណីខ្លះទៀត ត្រូវប្តីបោះបង់ចោលទៅមានគ្រួសារថ្មី និង ខ្លះទៀតត្រូវទទួលរងនូវអំពើហឹង្សាទៀតផង ។

- **ខ្វះមុខរបរ ដើមទុន និង ប្រាក់ចំណូល**

ដោយសារតែ ខ្វះជំនាញ និង ដើមទុន ក្នុងការប្រកបរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ជាកត្តាជំរុញ អោយជីវភាពរស់នៅមានការធ្លាក់ចុះពីមួយថ្ងៃទៅមួយថ្ងៃ ។ ពួកគេ បានបង្ខំចិត្តលក់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដូចជាៈ ដីស្រែ-ចំការ សត្វចិញ្ចឹម ។ល។ ដើម្បីដោះស្រាយការរស់នៅរយៈពេលខ្លី ។ ប្រាក់ចំណូលតិចតួចបំផុតបានមកពីការលក់កំលាំងពលកម្មនៅតាមមូលដ្ឋានរបស់គេ ។ ជាពិសេស នៅរដូវទឹកជំនន់ គ្រួសារដែលមានស្ត្រីជាមេគ្រួសារភាគច្រើន មិនមានមុខរបរ ដើម្បីរកប្រាក់ចំណូលប្រចាំថ្ងៃ ដើម្បីទ្រទ្រង់ជីវភាពរស់នៅ ដោយសារខ្វះមធ្យោបាយ និង ដើមទុន។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារក្រីក្រ មិនត្រូវបានទទួលសេវាកម្មឥណទានខ្នាតតូចពីស្ថាប័នហិរញ្ញវត្ថុនានាឡើយ ដោយហេតុផលជាច្រើន ដូចជា ពួកគេគ្មានមុខរបរច្បាស់លាស់ មិនសង្ឃឹមថាអាចមានលទ្ធភាពក្នុងការសងរំលោះត្រឡប់ទៅវិញ និង ខ្វះទំនាក់ទំនងជាមួយស្ថាប័នឥណទាន ជាដើម ។

- **ស្ថិតិ និងពត៌មានទាក់ទងនឹងស្ត្រីមេគ្រួសារ**

| ខេត្ត/ស្រុក | ចំនួនប្រជាជន | ចំនួនស្ត្រី | ចំនួនបុរស | %ស្ត្រីមេគ្រួសារ | %ភាពក្រីក្រ |
|---|---|---|---|---|---|
| ស្ថិតិទូទាំងកម្ពុជា | ១៣.៨០៦.៩២៣ | | | ២៩,២ % | |
| ខេត្តព្រៃវែង | ១.០៤៦.៤៦០ | ៥៤៧.០៣០ | ៤៩៩.៤៣០ | ១៧,៨៦ % | ៦០ % |
| ស្រុកស៊ីធរកណ្តាល | ៧១.៤២០ | ៣៨.១១៦ | ៣៣.៣០៤ | ១៩,៧៨ % | ៥៥ % |
| ស្រុកពាមជរ | ៦២.៩៨៨ | ៣២.២៣០ | ៣០.៧៥៨ | ២,១៦ % | ៤០ % |
| ខេត្តកណ្តាល | ១.១៩២.៤៩៩ | ៦១៧.៤១៤ | ៥៧៥.០៨៥ | ២៣,៩ % | ៦០ % |
| ស្រុកល្វាឯម | ៥៧.៧២៨ | ២៩.៧៩៣ | ២៧.៩៣៥ | ២,៤៥ % | ៦៥ % |
| ស្រុកលើកដែក | ៧៥.៣៦៨ | ៣៨.៨០៧ | ៣៦.៥៦១ | ២,០០ % | ៤០ % |

# ២. អនុសាសន៍ដើម្បីដោះស្រាយសេចក្តីត្រូវការរបស់ស្ត្រីមេគ្រួសារ

## ក. អនុសាសន៍ទូទៅ

- **ពត៌មានព្យាករណ៍ពីទឹកជំនន់ត្រូវធ្វើការផ្សព្វផ្សាយអោយបានញឹកញាប់ និងទូលំទូលាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា**





ពតិមានព្យាករណ៏តាមទូរទស្សន៏ និង វិទ្យុ គួរតែធ្វើការផ្សព្វផ្សាយអោយបានញឹកញាប់ ព្រមទាំង អានពតិមានព្យាករណ៏ផង ។ ចៀសវាងការផ្សាយតែពតិមានតែគ្មានសំលេង។ ការផ្សាយនេះគួរតែធ្វើការផ្សព្វផ្សាយអោយបាន ៣ ដងក្នុងមួយថ្ងៃនៅរដូវទឹកជំនន់ (ពេលព្រឹកម៉ោង០៨:០០ ពេលថ្ងៃត្រង់ម៉ោង ១២:០០ និង ពេលល្ងាចម៉ោង០៧:០០)។ ម្យ៉ាងទៀត ការផ្សព្វផ្សាយពតិមានព្យាករណ៏នេះគួរតែប្រើប្រាស់បណ្តាញពតិមានដែលមានស្រាប់នៅតាមសហគមន៏ ចៀសវាងការបង្កើតអោយមានបណ្តាញថ្មីបន្ថែមទៀត ។

- **គួរប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់របស់មន្ទីរ ឬ ការិយាល័យកិច្ចការនារី និង បណ្តាញអង្គការក្រៅរដ្ឋាភិបាល**




(យោងតាមព្រះរាជក្រឹត្យលេខ ០២០១/០៣៦ នស/រកទចុះថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការបង្កើត និង អនុក្រិត ស្តីពីប្រតិបត្តិការនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី លេខ៥៧ លេខអនក្រ. ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០០៦)

ក្រសួងកិច្ចការនារី បានរៀបចំអោយមាន មន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីស្រុក និង ស្ត្រីទទួលបន្ទុកកិច្ចការនារី និង កុមារថ្នាក់ឃុំ និង ភូមិ ។ នៅថ្នាក់ភូមិ និង ឃុំមានមន្ត្រីអាជ្ញាធរ ជាស្ត្រីសំរាប់ទទួលបន្ទុកកិច្ចការនារី និង កុមារ ។ ជួនកាលពួកគេជា សមាជិកអ្នកស្ម័គ្រចិត្ត សុខភាពភូមិ ឬ ជាអ្នកស្ម័គ្រចិត្តកាកបាទក្រហមភូមិ ។ ក្រៅពីប្រព័ន្ធរដ្ឋាភិបាល នៅមានបណ្តាញ អង្គការក្រៅរដ្ឋាភិបាល ដែលគេបានរៀបចំបណ្តាញស្ត្រីសំរាប់ធ្វើការងារទាក់ទងនឹងស្ត្រីដូចជា អប់រំ សិទ្ធិស្ត្រី អំពើហឹង្សាក្នុងគ្រួសារអប់រំពីជំងឺអេដស៍ ។ល ។ មានអនុសាសន៏ជាច្រើន ដែលបានស្នើសុំអោយមានការចូលពាក់ព័ន្ធស្ថាប័ន ឬអង្គការដែលធ្វើការងារផ្នែកស្ត្រីបានចូលរួមនៅក្នុងការអនុវត្តកម្មវិធីនេះ ។ ធ្វើយ៉ាងដូច្នេះ ទើបបញ្ហារបស់ស្ត្រីត្រូវបានយកចិត្តទុកដាក់ និង ឆ្លើយតបបានទៅនឹងសេចក្តីត្រូវការរបស់ស្ត្រី ។

- **ធ្វើការផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈ**

នៅតាមតំបន់ជនបទ បុរសភាគច្រើនបានចាកចេញពីលំនៅដ្ឋាន ដើម្បីស្វែងរកការងារធ្វើនៅតាមទីប្រជុំជន។ ដូច្នេះ ស្ត្រីជាអ្នកទទួលខុសត្រូវក្នុងការមើលថែទាំកូនចៅ សមាជិកគ្រួសារ និង ទ្រព្យសម្បត្តិ ។ នៅតាមតំបន់បែបនេះ មានការចូលរួមតិចតួចរបស់ស្ត្រីនៅក្នុងកិច្ចប្រជុំ និង ការចូលរួមធ្វើការសំរេចចិត្តផ្សេងៗ ព្រមទាំងពុំសូវមានឱកាសក្នុងការចូលរួម

វគ្គបណ្តុះបណ្តាល បង្កើនការយល់ដឹង និង ពង្រឹងសមត្ថភាព ពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និង វគ្គបណ្តុះបណ្តាលផ្សេងៗទៀត ។ នៅក្នុងស្ថានភាពបែបនេះ ធ្វើអោយគេមិនមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការឆ្លើយតបនឹងគ្រោះអាសន្នដោយខ្លួនគេបាន។ ហេតុដូច្នេះ ហើយទើបការងារបង្កើនការយល់ដឹងដល់ស្ត្រីពីវិធានការត្រៀមបង្ការ និង កាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ជាការងារចាំបាច់សំរាប់បង្កើនការយល់ដឹង និងបង្កអោយគេមានចំណេះដឹងអាចឆ្លើយតបនឹងបញ្ហាគ្រោះទឹកជំនន់ បានដោយខ្លួនគេ។



- **ផ្តល់សេវាកម្ម និង អនុវត្តកម្មវិធីដើម្បីបង្កើនជីវភាពរស់នៅរបស់ស្ត្រីមេគ្រួសារ**

បញ្ហាសំខាន់របស់ស្ត្រីមេគ្រួសារនៅតាមតំបន់ប្រឈមមុខនឹងគ្រោះទឹកជំនន់ គឺបញ្ហាជីវភាពរស់នៅរបស់គេមានដុនដាប ដោយសារពួកគេខ្វះមុខរបរច្បាស់លាស់ ខ្វះដើមទុនសំរាប់ប្រកបរបរចិញ្ចឹមជីវិត ខ្វះជំនាញ និង ចំណេះដឹងក្នុងការប្រកបរបរកសិ ខ្វះដីធ្លីសំរាប់បង្កបង្កើនផល (ដីត្រូវលក់) ។ ដូច្នេះ មុខរបរសំខាន់របស់គេ គឺការលក់កំលាំងពលកម្មដើម្បីចិញ្ចឹមជីវិត។ តាមការសិក្សា មានអនុសាសន៏ជាច្រើនបានផ្តល់អោយ ដើម្បីកែលំអស្ថានភាពរបស់ស្ត្រីមេគ្រួសារមានដូចតទៅ (១)ផ្តល់ចំណេះដឹង និង ជំនាញ ក្នុងការប្រកបរបរចិញ្ចឹមជីវិត, (២) បង្កលក្ខណៈអោយមានមុខរបរអចិន្ត្រៃយ៏ ដែលអាចធានាបាននូវប្រាក់ចំណូលប្រចាំថ្ងៃ តាមរយៈការបង្កើតអោយមានមុខរបរ និង ផ្តល់ដើមទុន ដើម្បីប្រកបមុខរបរ និង (៣) ជួយរកទីផ្សារដើម្បីធានានិរន្តរភាពនៃមុខរបរ ។ ក្រៅពីនេះ ត្រូវគិតគូរផ្តល់សេវាកម្មផ្សេង ដូចជា ការអប់រំ និង ថែទាំសុខភាព បង្កលក្ខណៈអោយស្ត្រីមេគ្រួសារ បានចូលរួមនៅក្នុងដំណើរការអភិវឌ្ឍន៏មូលដ្ឋាន (មានសំលេងក្នុងការសំរេចចិត្ត) ផ្តល់តួនាទី និង ការទទួលខុសត្រូវនៅតាមសហគមន៏ និងផ្តល់ឱកាសក្នុងការទទួលបានចំណេះដឹង និង ជំនាញផ្សេងៗ ជាដើម ។

## ៦_វិធានការដាក់លាក់ក្នុងការកាត់បន្ថយផលប៉ះពាល់គ្រោះទឹកជំនន់ លើស្ត្រីមេគ្រួសារនៅពេលអនាគត

១. រៀបចំចងក្រងក្រុមជួយខ្លួនឯង ដើម្បីបង្កលក្ខណៈ និង ឱកាសអោយស្ត្រីមេគ្រួសារអាចទទួល បានសេវាកម្មឥណទាន និង ជួយគ្នាទៅវិញទៅមកនៅតាមសហគមន៏ ។
២. រៀបចំយន្តការ ដើម្បីប្រើប្រាស់បណ្តាញរបស់ស្ថាប័នស្ត្រី ដើម្បីធានានូវការទទួល ផ្តល់ និង ចែករំលែកពត៏មាននានា ។
៣. ផ្តល់នូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈខ្នាតតូចតំរូវតាមសេចក្តីត្រូវការនៅមូលដ្ឋាន ឧ. បច្ចេកទេសកសិកម្ម ដាំដំណាំ ជំនាញខាងសិប្បកម្មខ្នាតតូច
៤. ផ្តល់ដើមទុន ដើម្បីប្រកបរបរខ្នាតតូច ។
៥. ផ្តល់ការយល់ដឹងអោយស្ត្រីមេគ្រួសារ-ស្ត្រីគ្រួសារក្រីក្របានយល់ដឹងពីសិទ្ធិជាមូលដ្ឋាន និង ពីយេនឌ័រ និងការអភិវឌ្ឍន៏តាមតំរូវការជាក់ស្តែង ។
៦. គាំទ្រពីអង្គការ និងរដ្ឋាភិបាល បញ្ចូលបញ្ហាទាំងឡាយរបស់ស្ត្រីជាមេគ្រួសារ ទៅក្នុងផែនការ អភិវឌ្ឍន៏ឃុំ ។

○ **គោលការណ៏និងសារៈសំខាន់នៃការចងក្រុមជួយខ្លួនឯង**

១- កសាងភាពរឹងមាំ ក្នុងការកសាងសាមគ្គីជួយគ្នាឯងក្នុងភូមិ
២- លើកកំពស់ការយល់ដឹងសិទ្ធិជាមូលដ្ឋាននៃសេក្តីត្រូវការរបស់ស្ត្រី-បុរស
៣- កាត់បន្ថយការរើសអើងលើស្ត្រី ស្ត្រីពិការ គ្រួសារក្រីក្រ

៤- ជួយស្តារស្ថានភាពជីវភាព ស្ត្រី និងគ្រួសារក្រីក្រ ពីបំណុល
៥- មាននិរន្តរភាពជីវភាពលើសន្តិសុខស្បៀង និងសេដ្ឋកិច្ច អប់រំសុខភាព បរិស្ថាន និងការធ្វើសេចក្តីសំរេចចិត្ត ក្នុងវិស័យនយោបាយ
៦- កសាងសុភមង្គលគ្រួសារ និងរួមអភិវឌ្ឍន៍សង្គម មានភាពទទួលខុសត្រូវ លើភាពឯករាជ្យជំរុញអោយពឹងលើខ្លួនឯងចេះទទួលខុសត្រូវលើសេដ្ឋកិច្ចមូលដ្ឋានលើផ្នែកចំណូលចំណាយ
៧- មានវិធានការពិសេស អោយស្ត្រីមានឋានៈតួនាទីក្នុងសហគមន៍ ជួយអោយមានយុត្តិធម៌ ក្នុងសហគមន៍ ។

## ៣. តួនាទីរបស់ស្ត្រីនៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ

នៅក្នុងប្រទេសកម្ពុជាស្ត្រីជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងរកប្រាក់ចំណូលដើម្បីគាំទ្រជីវភាពរស់នៅរបស់គ្រួសារ បន្ថែមលើការងារថែរក្សា និង ការចិញ្ចឹមបីបាច់កូនចៅ និង សមាជិកគ្រួសារ ។ ក្រៅពីការងារ ចម្បងទាំងពីរនេះ ស្ត្រីបានដើរតួនាទីសំខាន់បន្ថែមទៀតលើការងារអភិវឌ្ឍន៍ និង ការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅគ្រប់ថ្នាក់ ជាពិសេសនៅថ្នាក់មូលដ្ឋាន ។ ខាងក្រោមនេះ បង្ហាញពីតួនាទី ស្ត្រីនៅក្នុងការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ។

- **ជាអ្នកថែរក្សា និងថែទាំ**

នៅពេលធម្មតា និង ពេលមានគ្រោះអាសន្ន ស្ត្រីជាអ្នកមើលការថែទាំដល់សមាជិកគ្រួសារ ជាពិសេសក្មេងៗ, មនុស្សចាស់ និង អ្នកមានជំងឺ ព្រមទាំងមើលការខុសត្រូវសត្វចិញ្ចឹមទៀតផង ។ នៅតាមសហគមន៍ ស្ត្រីក៏មានតួនាទី ជាមន្ត្រីរាជការ ឬ ជាអ្នកជំនាញសំខាន់ៗផងដែរ ដូចជា ជាគ្រូពេទ្យ គ្រូបង្រៀន មន្ត្រីអាជ្ញាធរ ជាដើម ។

- **ស្ត្រីជាអ្នកអនុវត្តការងារគ្រប់គ្រងគ្រោះភ័យទឹកជំនន់**

ក្រៅពីការងារប្រចាំថ្ងៃស្ត្រីបានដើរតួនាទីសំខាន់ផងដែរទាក់ទងនឹងកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ មានដូចតទៅ ៖

○ **មុនពេលទឹកជំនន់**

- រក និង ទុកដាក់អុសដុត
- រក និង គ្រប់គ្រងចំណីសត្វ
- ស្វែងរកប្រាក់កំចី ដើម្បីប្រកបរបរផ្គត់ផ្គង់គ្រួសារ
- គិតគូរពីការស្តុកទុកស្បៀងអាហារ និង សំភារៈសំរាប់រដូវវស្សា ដូចជា ម្ហូបអាហារក្រៀម អង្ករ ថ្នាំពេទ្យ សំភារៈសង្គ្រោះ ប្រេងឥន្ធនៈ ទៀន ឈើគូស ថ្មពិល
- ធ្វើការកត់សំគាល់ពីទីកន្លែងដែលនៅជិតៗផ្ទះរបស់អ្នក អាចជាដីខ្ពស់ ឬ ទីទួល
- រៀបចំទុកដាក់នូវសំភារៈនិងឯកសារសំខាន់ៗនៅក្នុងថង់ប្លាស្ទិកនិងទុកដាក់ឱ្យផុតពីទឹក
- ត្រៀមរៀបចំជាមុន ថ្នាំសំរាប់ផលិតទឹកស្អាត (ក្លរ៉ាមីន សាច់ជូ អាល់បែត)
- រៀបចំទុល និង ពង្រឹងផ្ទះ ដោយចងបង់បាញ់ ដាក់ចន្ទុលផ្ទះ
- រៀបចំកន្លែងដាំបន្លែមផ្សំសំរាប់បរិភោគនៅរដូវទឹកជំនន់
- ស្វែងយល់ពីសេវាកម្មសុខភាព ដូចជា ការចាក់ថ្នាំបង្ការសំរាប់មុនស្ស និង សត្វ ដែលផ្តល់ដោយភ្នាក់មណ្ឌលសុខភាពពេទ្យសត្វ និង អាជ្ញាធរមូលដ្ឋាន
- ណែនាំសមាជិកគ្រួសារ ក្នុងការត្រៀមជាមុននូវសំភារៈសំរាប់ដាក់លើធ្នើរ ឬ សំរាប់ដឹកជញ្ជូនទៅកាន់ទួលសុវត្ថិភាព ។

### ○ ក្នុងពេលទឹកជំនន់

- ➢ តាមដានពតិមានព្យាករណ៍ និង ពតិមានប្រកាសភាពអាសន្នតាមរយៈវិទ្យុ ទូរទស្សន៍ ក្តារពតិមាន និង អាជ្ញាធរដែនដី
- ➢ ណែនាំសមាជិក គ្រួសារពីគ្រោះថ្នាក់នៃគ្រោះទឹកជំនន់ ដូចជា ណែនាំកូនក្មេង កុំឱ្យលេងទឹក ជាពិសេសកន្លែងបាក់ដី និងកន្លែងទឹកហូរខ្លាំង
- ➢ ណែនាំកូនកុំបរិភោគអាហារមិនស្អាត និង ទឹកឆ្អិនជានិច្ច
- ➢ គ្រប់គ្រងកូនចៅ ទ្រព្យសម្បត្តិ និង សត្វចិញ្ចឹមនៅលើទីទួលសុវត្ថិភាព
- ➢ ទទួលជំនួយមនុស្សធម៌ និង ចាត់ចែងប្រើប្រាស់នៅក្នុងគ្រួសារ
- ➢ រកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ ដូចជាៈ រត់ទូកដរ នេសាទខ្នាតតូច ដាំបន្លែបង្ការ
- ➢ ប្រយ័ត្នសត្វមានពីសដូចជាៈ ពោះ ខ្យយ ក្អែម ដោយដាក់ ស្លឹកគ្រៃ និង ផ្លែក្រូចសើច
- ➢ ជូនកូនទៅសាលារៀននិងទទួលកូនត្រឡប់មកផ្ទះវិញត្រូវទៅរកទីទួល សុវត្ថិភាព
- ➢ បើកូនមានជំងឺត្រូវបញ្ជូនទៅពេទ្យដែលនៅជិតបំផុត ។

### ○ ក្រោយពេលទឹកជំនន់

➢ សំអាតផ្ទះសម្បែង បរិវេណជុំវិញលំនៅដ្ឋាន និង កន្លែងចិញ្ចឹមសត្វ ។ លុបថ្លុក ឬ កន្លែង ណាដែលមានដក់ទឹកស្អុយ ដែលជាកន្លែងមូសពង ជាដើម

➢ សំអាតសំភារៈដាក់ទឹកប្រើប្រាស់ ដូចជា ពាងទឹក ធុងទឹក ជាដើម ត្រូវធានាថា សំភារៈទាំងនោះត្រូវ បានសំលាប់មេរោគមុននឹងប្រើប្រាស់

- ➢ គ្រប់គ្រងសុខភាពសមាជិកគ្រួសារ
- ➢ ស្វែងរកពូជស្រូវ និង បន្លែ...ជាដើម ដើម្បីបង្កបង្កើនផលឡើងវិញ នៅរដូវសំរក
- ➢ មើលថែទាំសមាជិគ្រួសារ ដូចជា ណែនាំក្មេងៗកុំឱ្យឡើងលេងលើដំបូលផ្ទះ ឬគំនរឈើ បាក់បែក
- ➢ រកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ ។
- ➢ ហាល និង សំងួតរបស់របរសើមៗ ។

## ● ស្ត្រីជាអ្នករៀបចំផែនការនៅថ្នាក់សហគមន៍

ភាគច្រើនស្ត្រី ជាអ្នកដែលរស់នៅអចិន្ត្រៃយ៍ និង ជាអ្នកថែទាំកូនចៅ សមាជិកគ្រួសារ និង ទ្រព្យសម្បត្តិ នៅពេលដែលស្វាមីរបស់គេចាកចេញពីផ្ទះដើម្បីរកប្រាក់ចំណូលនៅទីប្រជុំជនឆ្ងាយៗ ។ ដូច្នេះហើយបានជា នៅពេលមានប្រជុំផ្សេងៗទាក់ទងនឹងការរៀបចំផែនការ ឬ កំនត់បញ្ហា និង សេចក្តីត្រូវការផ្សេងៗ តែងតែមានវត្តមានរបស់ស្ត្រីនៅក្នុងកិច្ចប្រជុំទាំងអស់នេះនៅតាមមូលដ្ឋាន ។ ហេតុដូច្នេះ ហើយបានជា គេមានឱកាសនៅក្នុងការរៀនសូត្រ និង ទទួលបានជំនាញផ្សេង ៗ ។

## ● ស្ត្រីជាអ្នកផ្សព្វផ្សាយពតិមានផ្សេងៗ



ខណៈដែលស្ត្រីនៅជាអចិន្ត្រៃយ៍ ក្នុងមូលដ្ឋានរបស់គេ ។ ពួកគេមានទំនាក់ទំនងនិងបណ្តាញរបស់គេនៅជិតៗគ្នាពីផ្ទះមួយទៅផ្ទះមួយ និង ពីកន្លែងមួយទៅកន្លែងមួយទៀត ។ ដូច្នេះ នៅពេលគេទទួលបានពតិមានថ្មីៗទាក់ទងនឹងមុខសញ្ញាបង្គ្រោះមហន្តរាយ និង ពតិមាន ព្យាករណ៍ពីកំពស់ទឹក និង ពតិមានប្រកាសភាពអាសន្នផ្សេងៗ គេតែងតែ

ផ្សព្វផ្សាយ ឬ បញ្ជូនពត៌មានបន្តដល់អ្នកជិតខាងយ៉ាងមានប្រសិទ្ធិភាព និង ទាន់ពេលវេលា ។

## ៤. សកម្មភាពអនុវត្តដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ស្ត្រីមេគ្រួសារក្រោមគំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ ផ្នែកទី៤ កម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់របស់គណៈកម្មការទន្លេមេគង្គ

ឆ្លើយតបទៅនឹងសេចក្តីត្រូវរបស់ស្ត្រីមេគ្រួសារ ដែលបានចង្អុលបង្ហាញក្នុងការសិក្សា មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) បានសហការជាមួយអង្គការបំលាស់ប្តូរជាវិជ្ជមានសំរាប់កម្ពុជា (PCC)។ អង្គការបំលាស់ប្តូរជាវិជ្ជមានសំរាប់កម្ពុជា (PCC) ជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បង្កើតឡើងដើម្បីធ្វើការផ្តោតសំខាន់លើការលើកស្ទួយសិទ្ធិស្ត្រី បង្កើនសិទ្ធិអំណាច និង បង្កើនការចូលរួមរបស់ស្ត្រី នៅក្នុងនយោបាយ និង ការងារអភិវឌ្ឍន៍។ អង្គការនេះធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយស្ថាប័ន រដ្ឋាភិបាល ជាពិសេស ក្រសួងកិច្ចការនារី និង សហការជាមួយអង្គការសង្គមស៊ីវិលជាតិ និង អន្តរជាតិនានា នៅក្នុងប្រទេសកម្ពុជា។ ដើម្បីធានាបាននូវនិរន្តរភាព និង ដើម្បីបង្កើនសមត្ថភាពស្ថាប័ន និង អង្គការសង្គមស៊ីវិលលើការគ្រប់គ្រងគ្រោះមហន្តរាយ ។ ចាប់ពីខែមិថុនា ដល់ ខែកញ្ញា ឆ្នាំ ២០០៧ មជ្ឈមណ្ឌលត្រៀមបង្ការ គ្រោះមហន្តរាយអាស៊ី បានធ្វើជាដៃគូជាមួយអង្គការបំលាស់ប្តូរជាវិជ្ជមានសំរាប់កម្ពុជា ដើម្បីដើរតួនាទី ជាអ្នកជួយផ្តល់ការងារបច្ចេកទេស និង ជួយពង្រឹងសមត្ថភាពមន្ទីរកិច្ចការនារីខេត្ត-ស្រុក និង ជនបង្គោល ទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ នៅតាមតំបន់គោលដៅនៃគំរោងនៅខេត្តកណ្តាលមាន០២ស្រុក( ស្រុកល្វាឯម និង ស្រុកលើកដែក) និងនៅខេត្តព្រៃវែងមាន០២ស្រុក ( ស្រុកពាមជរ និង ស្រុកស៊ីធរកណ្តាល) ។ ក្រោមកិច្ចសហប្រតិបត្តិការនេះ អង្គការបំលាស់ប្តូរជាវិជ្ជមានសំរាប់កម្ពុជា បានអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម :



១. បង្កើនសមត្ថភាព មន្ទីរកិច្ចការនារីថ្នាក់ខេត្ត-ស្រុក និង ជនបង្គោលទទួលបន្ទុកកិច្ចការនារី ឃុំលើវិធានការត្រៀមបង្ការ និង កាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ ដើម្បីអោយគេអាច ធ្វើការផ្សព្វផ្សាយដល់ស្ត្រីមេគ្រួសារនៅតាមភូមិរបស់គេ។

២. ធ្វើការផ្សព្វផ្សាយពីវិធានការត្រៀមបង្ការ និង កាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ ដល់ស្ត្រីមេគ្រួសា រនៅតាមភូមិ ដោយមានការជួយសំរបសំរួលពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ

៣. សិក្សាពីបញ្ហា សេចក្តីត្រូវការ និង យុទ្ធសាស្ត្រដោះស្រាយបញ្ហារបស់ស្ត្រីមេគ្រួសារ និង ធ្វើការសំរបសំរួលជាមួយគំរោងអភិវឌ្ឍន៍នានា ដើម្បីបញ្ចូលយុទ្ធសាស្ត្រនេះទៅក្នុងផែនការ អភិវឌ្ឍន៍មូលដ្ឋាន ។

៤. សំរបសំរួលអោយមានការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការនៃការកែសំរួលកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្ត និង ស្រុក ដើម្បីធានាថា បញ្ហា និងសេចក្តីត្រូវការទាក់ទងនឹងស្ត្រី ត្រូវបានយកចិត្តទុកដាក់ និង បញ្ចូលនៅក្នុងកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្ត និង ស្រុក។

## ៩. បទពិសោធន៏ និង មេរៀនទទួលបានពីការអនុវត្តន៏គំរោងសាកល្បង

- ស្ថាប័នកិច្ចការនារីថ្នាក់ខេត្ត ស្រុក និង ឃុំ និង អង្គការសង្គមស៊ីវិល ដែលធ្វើការផ្តោតសំខាន់លើបញ្ហានារីមានបទពិសោធន៏ច្រើននៅក្នុងការអនុវត្តន៏កម្មវិធីនានា ដូចជា ការលុបបំបាត់ អំពើហឹង្សាគ្រួសារ ការអប់រំសុខភាព ប៉ុន្តែគេមិនមានបទពិសោធន៏ និង ចំណេះដឹងលើ ការអនុវត្តកម្មវិធីទាក់ទងនឹងការគ្រប់គ្រោះភ័យនៃគ្រោះមហន្តរាយ ។ តែបទពិសោធន៏របស់គេ អាចយកមកប្រើប្រាស់បានល្អលើការងារគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ ។ ដូច្នេះហើយ បានជាការចូលពង្រឹងសមត្ថភាពរបស់ស្ថាប័ន និង អង្គការដែលធ្វើការផ្នែកស្ត្រីលើការងារគ្រប់គ្រងគ្រោះមហន្តរាយ គឺជាការងារមួយ ដែលមានអាទិភាពខ្ពស់ដែលគួរយកចិត្តទុកដាក់ ។

- ការរៀបចំ និង ការអនុវត្តន៏កម្មវិធីដើម្បីដោះស្រាយបញ្ហារបស់ជនងាយរងគ្រោះបែបនេះ នៅតាមសហគមន៏ជាការឆ្លើយតបបានយ៉ាងមានប្រសិទ្ធភាពទៅនឹងសេចក្តីត្រូវការពិតជាក់ស្តែងរបស់គេ ។

- ការពង្រឹសមត្ថភាពរបស់ស្ថាប័ននារី ជាពិសេស ជនបង្គោលទទួលបន្ទុកកិច្ចការនារីនៅថ្នាក់មូលដ្ឋាន ជាយន្តការមួយមានប្រសិទ្ធិភាព ដែលអាចធានាបាននូវនិរន្តរភាពនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និង ពង្រឹងបាននូវការពង្រីកបន្ថែមកម្មវិធីបែបនេះទៅបណ្តាតំបន់ដែលប្រឈមមុខនឹងបញ្ហាប្រហាក់ប្រហែលគ្នា

- ការសំរបសំរួលកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ថ្នាក់ជាមួយស្ថាប័នកិច្ចការនារីគ្រប់ថ្នាក់ផងនោះ អាចជួយពង្រឹងបាននូវកិច្ចសហការ និង ជួយគ្នាទៅវិញទៅមកនៅគ្រប់ថ្នាក់តាំងពីថ្នាក់លើ ដល់ថ្នាក់ក្រោម និង ពីស្ថាប័នមួយ ទៅស្ថាប័នមួយផ្សេងទៀត ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ។

- ការធ្វើអោយមានការពាក់ព័ន្ធពីអង្គការសង្គមស៊ីវិល និង អង្គការមិនមែនរដ្ឋាភិបាល ដើម្បីដើរតួនាទីជាអ្នកសំរបសំរួល និង ផ្តល់ការងារបច្ចេកទេសដល់ស្ថាប័នរដ្ឋាភិបាល គឺជាវិធីសាស្រ្តថ្មីមួយ ដែលអាចធានាបាននូវនិរន្តរភាពយូរអង្វែង ។

## គំរោងពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS)

ដោយបានទទួលជំនួយមូលនិធិពីភ្នាក់ងារសហប្រតិបត្តិការជំនួយបច្ចេកទេសអន្តរជាតិ ប្រទេសអាឡឺម៉ង់ (GTZ), គំរោង ពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS), ដែលជាផ្នែកមួយនៃកម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់ (FMMP) បានអនុវត្តន៍ដោយគណៈកម្មាការទន្លេមេគង្គ (MRC) សហការជាមួយ មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) ។ ដោយធ្វើការពង្រឹងសមត្ថភាពរបស់អ្នកគ្រប់គ្រងគ្រោះអាសន្ន សហគមន៍ និង អាជ្ញាធរស៊ីវិលគ្រប់ថ្នាក់ លទ្ធផលទាំងនេះ ដើម្បីពង្រឹងសមត្ថភាពរបស់ប្រទេសជាសមាជិកនីមួយៗ ក្នុងការត្រៀមបង្ការ និង កាត់បន្ថយគ្រោះទឹកជំនន់ប្រចាំឆ្នាំ ដោយពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រោះអាសន្ននៅក្នុងបណ្តាប្រទេស ដែលតាមដងទន្លេមេគង្គ ។

---

### ដៃគូអនុវត្តន៍គំរោង:


**លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRC)**
ប្រអប់សំបុត្រលេខ ៦១០១, អគារលេខ ១៨ បានស៊ីថានេនូវ, ខ័ណ្ឌស៊ីកុតថាបុង,
ក្រុងវៀងច័ន្ទ ០១000 ប្រទេសឡាវ
ទូរស័ព្ទ: (៨៥៦) ២១ ២៦៣ ២៦៣, ហ្វាក់: (៨៥៦) ២១ ២៦៣ ២៦៤
អ៊ីម៉ែល: mrcs@mrcmekong.org **វ៉ិបសាយ: http://www.mrcmekong.org**

**គណៈកម្មការជាតិទន្លេមេគង្គ កម្ពុជា (CNMC)**
ផ្ទះលេខ ២៣, មហាវិថីម៉ៅសេទុង, ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ: (៨៥៥) (២៣) ២១៨ ៧២៧ ហ្វាក់: (៨៥៥) (២៣) ២១៨ ៥០៦
អ៊ីម៉ែល: cnmcs@cnmc.gov.kh **វ៉ិបសាយ: http://www.camnet.com.kh/cnmcs**

**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)**
ផ្លូវលេខ ៥១៦, សង្កាត់ទួលសង្កែ, ខ័ណ្ឌឬស្សីកែវ, ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ/ ហ្វាក់: (៨៥៥) (២៣) ៨៨២ ០៤៥

**លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ខេត្តកណ្តាល (PCDM)**
ឃុំដើមមាន, ស្រុកតាខ្មៅ, ខេត្តកណ្តាល ប្រទេសកម្ពុជា
ទូរស័ព្ទ: (៨៥៥) (២៣) ៤២៥៥៥៥

**លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ខេត្តព្រៃវែង (PCDM)**
ឃុំកំពង់លាវ ស្រុកកំពង់លាវ, ខេត្តព្រៃវែង ប្រទេសកម្ពុជា
ទូរស័ព្ទ: (៨៥៥) (៤៣) ៩៤៤ ៥៤៦

**មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)**
ប្រអប់សំបុត្រលេខ ០៤, ក្លងលួង, ផាថុមថានី ១២១២០ ប្រទេសថៃ
ទូរស័ព្ទ: (៦៦) ០២ ៥១៦ ៥៩០០ ឬ (៦៦)០២ ៥១៦ ៥៩១០
ហ្វាក់: (៦៦) ០២ ៥២៤ ៥៣៥០ ឬ (៦៦) ០២ ៥២៤ ៥៣៦០
អ៊ីម៉ែល: adpc@adpc.net **វ៉ិបសាយ: www.adpc.net**

**បំលាស់ប្តូរជាវិជ្ជមានសំរាប់កម្ពុជា**
ផ្ទះលេខ ៣៥ D ផ្លូវលេខ ៣៦៥ សង្កាត់ បឹងកេងកង ៣ ខ័ណ្ឌ ចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: ០៩២ ៩៩៣ ៧៧៥
អ៊ីម៉ែល: sochivannyhoy@yahoo.com



ឧបត្ថម្ភដោយ:

**ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស ប្រទេសអាឡឺម៉ង់ (GTZ)**